**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**លេខ...០៥/១៨..នព**

# សេចក្តីថ្លែងការណ៍អ្នកនាំពាក្យក្រសួងការពារជាតិ

ក្រសួងការពារជាតិ សូមប្រកាសថ្កោលទោសយ៉ាងដាច់អហង្កា និងប្រឆាំងដាច់ខាតចំពោះ ទណ្ឌិត សម រង្ស៊ី ដែលបានលួចចុះកិច្ចព្រមព្រៀងកាត់ទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ទៅឱ្យជនជាតិភាគតិចវៀតណាម។

យើងខ្ញុំទាំងអស់គ្នា ជាកងយោធពលខេមរភូមិន្ទ ចាត់ទុកថា ការចុះហត្ថលេខាជាមួយឈ្មោះ កុក ស (Kok Ksor) មេដឹកនាំជនជាតិភាគតិចវៀតណាម Degar ឬម៉ុងតាញ៉ា ដើម្បីឱ្យជនជាតិនេះ គ្រប់គ្រងខេត្តចំនួន៤របស់កម្ពុជា រួមមានខេត្តមណ្ឌលគិរី, រតនគិរី, ក្រចេះ និងខេត្តស្ទឹងត្រែង ដែលធ្វើឡើងដោយ ទណ្ឌិត សម រង្ស៊ី អតីតប្រធានគណបក្សសង្គ្រោះជាតិ កាលពីឆ្នាំ២០១៣នោះ គឺជាអំពើក្បត់ជាតិ រំលោភរដ្ឋធម្មនុញ្ញ ដែលជាទង្វើមួយមិនអាចអត់ឱន បានជាដាច់ខាត។

ក្រសួងការពារជាតិ សូមគាំទ្រចំពោះចំណាត់ការរបស់ រាជរដ្ឋាភិបាលកម្ពុជា និងសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ ក្នុងការអនុវត្តប្រឆាំងចំពោះទង្វើក្បត់ជាតិរបស់ទណ្ឌិតរូបនេះ និងអំពាវនាវដល់ ស្ថាប័នតុលាការ នៃព្រះរាជាណាចក្រកម្ពុជា សូមចាត់វិធានការឱ្យបានម៉ឺងម៉ាត់ និងផ្តន្ទាទោសជនក្បត់ជាតិ សម រង្ស៊ី ទៅតាមច្បាប់ ឱ្យបានធ្ងន់ធ្ងរបំផុត ដោយគ្មានការលើកលែងចំពោះទង្វើ ក្បត់ជាតិ និងប្រជាជន នេះឡើយ៕

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១៨

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៤ អ៊ីម៉ែល៖ generalsec@mod.gov.kh